**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**មជ្ឈមណ្ឌលជាតិពិសោធន៍សុខាភិបាល**

**គណៈកម្មាធិការលទ្ធកម្ម**

លេខ : ..030/18...អល/មជពស

# សេចក្តីជូនដំណឹង

# ស្តីពី

# ការអញ្ជើញចូលរួមដេញថ្លៃការផ្គត់ផ្គង់ប្រតិករគីមី ជូនមជ្ឈមណ្ឌលជាតិពិសោធន៍សុខាភិបាល ឆ្នាំ២០១៨

មជ្ឈមណ្ឌលជាតិពិសោធន៍សុខាភិបាល សូមជម្រាបជូនដំណឹងដល់បណ្តាក្រុមហ៊ុន /សហគ្រាស (គិតទាំងសហគ្រាសឯកត្តបុគ្គល ) ទាំងអស់ ដែលបានចុះបញ្ជីត្រឹមត្រូវក្នុង ព្រះរាជាណាចក្រកម្ពុជា អោយបានជ្រាបថា÷ មជ្ឈមណ្ឌលជាតិពិសោធន៍សុខាភិបាល នឹងដាក់ឱ្យដេញថ្លៃជាសាធារណៈ ដើម្បីជ្រើសរើសអ្នកផ្គត់ផ្គង់ ប្រតិករគីមីជូនមជ្ឈមណ្ឌលជាតិពិសោធន៍សុខាភិបាល ដោយប្រើប្រាស់ថវិកាសេវា របស់មជ្ឈមណ្ឌលជាតិពិសោធន៍សុខាភិបាល ដែលបានអនុម័ត ឆ្នាំ២០១៨ ។

មជ្ឈមណ្ឌលជាតិពិសោធន៍សុខាភិបាល បានរៀបចំឯកសារសម្រាប់ក្រុមហ៊ុន /សហគ្រាសបំពេញដើម្បីចូលរួមដេញថ្លៃ និងមានដាក់លក់នៅ អង្គភាពលទ្ធកម្ម មជ្ឈមណ្ឌលជាតិ អាគារលេខ 245H ផ្លូវជាតិលេខ 6A ភូមិគៀនឃ្លាំង សង្កាត់ព្រែកលៀប ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ ចាប់ពីថ្ងៃទី ១៩ ខែ ឧសភា ឆ្នាំ ២០១៨ តទៅរៀងរាល់ម៉ោងធ្វើការ (ទូរស័ព្ទទំនាក់ទំនង លេខ 023 432169, 012 636349 ) ។

កាលបរិច្ឆេទឈប់ទទួលសំណើដេញថ្លៃ នៅម៉ោង ១០ព្រឹក ថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ២០១៨ ។

ការបើកសំណើដេញថ្លៃ នឹងប្រព្រឹត្តទៅនៅអង្គភាពលទ្ធកម្មមជ្ឈមណ្ឌលជាតិ តាមអាសយដ្ឋានខាងលើ វេលាម៉ោង១០ព្រឹក ថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ២០១៨ ។

ក្រុមហ៊ុន/សហគ្រាសដែលមានសម្ព័ន្ធភាពជាមួយគ្នា ឬមានប្រភពតែមួយ អាចដាក់សំណើដេញថ្លៃបានតែមួយគត់ ។

ក្រុមហ៊ុន /សហគ្រាសដែលមានបំណងចូលរួមដេញថ្លៃ សូមអញ្ជើញទាក់ទងជាមួយអង្គភាពលទ្ធកម្ម ដើម្បីទិញឯកសារដេញថ្លៃ និងសាកសួរព័ត៌មាន ដែលទាក់ទងនឹងការដេញថ្លៃនេះ ។

ថ្ងៃសុក្រ ៤កើត ខែជេស្ឋ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២

រាជធានីភ្នំពេញ.ថ្ងៃទី ១៨ ខែ ឧសភា ឆ្នាំ២០១៨

**ប្រធានគណៈកម្មាធិការលទ្ធកម្ម**

**ឧត្តមការី ទេព-គីឡា**

ចម្លងជូន÷

-អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ

-អង្គភាពប្រឆាំងអំពើពុករលួយ

-ឯកសារ កាលប្បវត្តិ